# នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១៥

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Feb-2015, 15:25
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើតាមវិធាន ៨៧(៤)របស់ នួន ជា ស្នើសុំឲ្យទទួលយកឯកសារទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យូរ ឧត្តរា

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម Claudia FENZ

Original EN:

ឡេង ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

វ៉ីន ពៅ

ទី ស្រ៊ីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Èlodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Michael Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**<u>ផ្ញើជូន៖</u>**

**<u>ការិយាល័យសហព្រះរាជអាជ្ញា៖</u>**

ជា លាង

Nicholas KOUMJIAN

សេង ប៊ុនឃាង

William SMITH

**<u>ជនជាប់ចោទ៖</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីការពារក្តី៖</u>**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

Olivier BAHOUGNE
Patrick BAUDOUIN
Beine YE

## I. សេចក្តីផ្តើម

1. នៅថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១៥ សហមេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") បានដាក់ *សំណើរបស់ នួន ជា តាមវិធាន ៨៧(៤) សុំឱ្យទទួលយកឯកសារពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី* ("សំណើ")[1]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមឆ្លើយតបដោយស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធចោលសំណើនេះ។

## II. ច្បាប់ជាធរមាន

2. វិធានផ្ទៃក្នុងរបស់តុលាការផ្តល់ឆន្ទានុសិទ្ធិទូលាយឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកឯកសារធ្វើជាភស្តុតាង[2] កាលណាឯកសារបំពេញលក្ខណៈវិនិច្ឆ័យស្តីពីភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដូចមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង[3]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ភស្តុតាងដែលត្រូវយកមកពិចារណាតាមវិធាន ៨៧(៣) ត្រូវតែបំពេញតាមបទដ្ឋាននៃ *សេចក្តីបញ្ជាក់បឋម* ស្តីពីភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព[4]។ ដើម្បីសម្រេចលើភាពពាក់ព័ន្ធ អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញថា "ទោះបីជាក្របខណ្ឌច្បាប់ អ.វ.ត.ក. មិនបានតម្រូវក៏ដោយ ក៏ការចង្អុលបង្ហាញពីភាពពាក់ព័ន្ធ អាចជួយដល់អង្គជំនុំជម្រះក្នុងការវាយ

---

[1] សំណើតាមវិធាន ៨៧(៤)របស់ នួន ជា ស្នើសុំឱ្យទទួលយកឯកសារទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ឯកសារ E337 ថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១៥។

[2] វិធាន ៨៧(១) នៃ វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មទី ៨ ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១ (ដែលចែងថា "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក")។

[3] វិធាន ៨៧(៣) *ដូចខាងលើ* (ដែលចែងថា "អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឱ្យពិនិត្យភស្តុតាង បើយល់ឃើញថា៖ ក-មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា, ខ-មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ, គ-មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង, ឃ-ច្បាប់មិនអនុញ្ញាត ឬ ង-មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។")។

[4] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង "ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកមួយចំនួននៃឯកសារ E114, E114/1, E131/1/9, E131/6, E136 និង E158," E162, ថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០១២ កថាខណ្ឌ ២។ ចូរមើលផងដែរ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង "ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើតាមវិធាន ៨៧(៤) របស់សហព្រះរាជអាជ្ញា, ជនជាប់ចោទ នួន ជា និង ខៀវ សំផន (ឯកសារ E236/4/1, E265, E271, E276, AND E276/1)," E276/2 កថាខណ្ឌ ២ ថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៣ (ហៅកាត់ថា "អនុស្សរណៈស្តីពីឯកសារថ្មី")។

តម្លៃថាតើភស្តុតាងដែលត្រូវបានស្នើ បំពេញតាមលក្ខណវិនិច្ឆ័យនៃវិធាន៨៧(៣) នៃផ្ទៃក្នុងដែរឬទេ"។[5]

3. វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យអង្គជំនុំជម្រះទទួលយកភស្តុតាងថ្មីដែលមានប្រយោជន៍ដល់ការស្វែងការពិត និងស្របតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ក្នុងករណីដែលភស្តុតាងនោះមិនទាន់មានមុនពេលបើកការជំនុំជម្រះ ឬមិនអាចត្រូវបានរកឃើញតាមរយៈការយកចិត្តទុកដាក់ដ៏សមស្របទេ[6]។ អង្គជំនុំជម្រះនឹងចាត់ទុកឯកសារដែលមិនត្រូវបានដាក់ចូលក្នុងបញ្ជីរបស់ភាគីតាមវិធាន ៨០(៣) ថាជាភស្តុតាងថ្មី តាមវិធាន ៨៧(៤)[7]។

4. អង្គជំនុំជម្រះអាចទទួលយកភស្តុតាងថ្មី ដែលមិនពេញតាមលក្ខខណ្ឌតម្រូវនៃភាពទាន់ពេលវេលា និងការយកចិត្តទុកដាក់សមស្របដែលចែងក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ប្រសិនបើភស្តុតាងពាក់ព័ន្ធផ្ទាល់ទៅនឹងវត្ថុសម្ភារៈដែលបានដាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយ ឬក្នុងសក្ខីកម្មសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវផ្តល់សក្ខីកម្ម និងផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃលើប្រភពនៃភស្តុតាងទាំងនោះរួមជាមួយគ្នា[8]។ កាលណាភាគីព្យាយាមសុំឱ្យទទួលយកភស្តុតាងដោយផ្អែកតាមមូលដ្ឋានថាមានទំនាក់ទំនងទៅនឹងសក្ខីកម្មនាពេលខាងមុខ ភាគី

---

[5] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 កថាខណ្ឌ ២៩ ថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១២។ ចូរមើលផងដែរ "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៩២ ទាក់ទងនឹងសូចនាអំពីការជឿទុកចិត្តចំពោះឯកសារចំនួន ៩៧៨ ដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលអាចកោះហៅ សម្រាប់សវនាការបីសប្តាហ៍"ដំបូង" ឯកសារ E158 កថាខណ្ឌ ៣ ថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០១១ (ដែលបានផ្តល់បញ្ជីសូចនា មិនទាំងស្រុងអំពីភាពអាចជឿជាក់បាន រួមទាំងចរិតលក្ខណៈផ្ទៃក្នុង (ដូចជា កំណត់សំគាល់លេខកូដ អ្នកនិពន្ធដែលបានកំណត់អត្តសញ្ញាណ ចំណុចផ្គុំគ្នាក្នុងខ្លឹមសារឯកសារ) និងចរិតលក្ខណៈខាងក្រៅ (ដូចជា ភាពស៊ីចង្វាក់គ្នា ការកំណត់អត្តសញ្ញាណ និងការរកឃើញ))។

[6] អនុស្សរណៈស្តីពីឯកសារថ្មី កថាខណ្ឌ ៣។

[7] ដូចខាងលើ កថាខណ្ឌ ២។

[8] ដូចខាងលើ។ *ចូរអានផងដែរ* សេចក្តីសម្រេចទាក់ទងនឹងឯកសារថ្មីៗនិងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ E190 ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១២ កថាខណ្ឌ ២១ និង អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង "ចម្លើយតបទៅនឹងសំណើសុំទីពីររបស់លោក អៀង សារី អនុលោមតាមវិធាន ៨៧(៤) ទាក់ទងនឹងឯកសារដែលប្រើប្រាសក្នុងអំឡុងពេលសាកសួរដេញដោលអ្នកជំនាញ David CHANDLER ឯកសារ E172/24/5 ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០១២។

ត្រូវតែដាក់សំណើសុំតាមវិធាន ៨៧(៤) ជូនអង្គជំនុំជម្រះយ៉ាងហោចណាស់ឱ្យបានពីរសប្ដាហ៍មុនពេលសវនាការស្ដាប់សក្ខីកម្មដែលពាក់ព័ន្ធនោះ[9]។

## III. ការពិភាក្សា

5. បើពិនិត្យលើបញ្ហាបឋម សំណើរបស់មេធាវីការពារក្ដីគឺមិនត្រឹមត្រូវតាមនីតិវិធីទេ។ រាល់សំណើសុំឱ្យទទួលយកភស្ដុតាងថ្មី តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ត្រូវតែធ្វើឡើងឱ្យបានទាន់ពេលវេលា ពោលគឺ មុនពេលសវនាការស្ដាប់សក្ខីកម្មរបស់សាក្សី អ្នកជំនាញ ឬដើមបណ្ដឹងរដ្ឋប្បវេណី។ ការតម្រូវឱ្យភាគីដាក់សំណើតាមវិធាន ៨៧(៤) យ៉ាងហោចណាស់ឱ្យបានពីរសប្ដាហ៍មុនពេលបើកសវនាការស្ដាប់សក្ខីកម្ម គឺជាទម្លាប់អនុវត្តរបស់អង្គជំនុំជម្រះតាំងពីមុនរហូតមកដល់ពេលនេះ[10]។ មេធាវីការពារក្ដីទទួលបានឯកសារលេខ ២[11], ៤ និង ៥ នៅចុងខែវិច្ឆិកា ឆ្នាំ ២០១៤[12]។ មេធាវីការពារក្ដីក៏បានដឹងជាមុនពីសក្ខីកម្មរបស់អ្នកស្រី សុផានី លើឯកសារលេខ ១ ដែលជាសៀវភៅដែលគេអាចរកបានជាសាធារណៈ។ ចំពោះឯកសារផ្សេងទៀត (ឯកសារលេខ ២ ឬ ៣) ត្រូវ

[9] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកំពស់ប្រសិទ្ធភាពនៃសវនាការ" ឯកសារ E218 ថ្ងៃទី ៣ ខែសីហា ឆ្នាំ ២០១២ កថាខណ្ឌ ២២។ ចូរអានផងដែរ អនុស្សរណៈស្ដីពីឯកសារថ្មី កថាខណ្ឌ ២។

[10] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកំពស់ប្រសិទ្ធភាពនៃសវនាការ" ឯសការ E218 ថ្ងៃទី ៣ ខែសីហា ឆ្នាំ ២០១២ កថាខណ្ឌ ២២។ ចូរអានផងដែរ អនុស្សរណៈស្ដីពីឯកសារថ្មី កថាខណ្ឌ ២។

[11] ចំពោះឯកសារលេខ ២ តាមន័យក្នុងប្រយោគទីពីរនៃកថាខណ្ឌទី ៨ សំណើចែងមិនច្បាស់ថាតើមេធាវីការពារក្ដីទទួលបានឯកសារនៅចុងខែវិច្ឆិកាដែរឬទេ, តាមន័យក្នុងប្រយោគទីប្រាំនៃកថាខណ្ឌទី ៨ យើងមិនដឹងថាតើមេធាវីការពារក្ដីបានទទួលបន្ទាប់ពីការស្រាវជ្រាវបន្ថែមទាក់ទងទៅនឹងអ្នកស្រី អ៊ុំ សុផានី បន្ទាប់ការផ្ដល់សក្ខីកម្មរបស់គាត់នៅថ្ងៃទី ២២ ខែមករា ឆ្នាំ ២០១៥ នោះដែរ។ ការភ័ន្តច្រឡំនេះអាចបណ្ដាលមកពីកំហុសក្នុងការវាយអត្ថបទ។

[12] សំណើតាមវិធាន ៨៧(៤)របស់ នួន ជា ស្នើសុំឱ្យទទួលយកឯកសារទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ សុផានី ឯកសារ E337 ថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១៥ ត្រង់កថាខណ្ឌ ៨។

បាន “ទទួលបាន... បន្ទាប់ពីបានធ្វើការស្រាវជ្រាវបន្ថែមពាក់ព័ន្ធនិងអ្នកស្រី សុផានី”។[13] ដូច្នេះភាគីអាចរកបានឯកសារទាំងអស់ មុនពេលបើកសវនាការលើសំណុំរឿង ០០២/០២។

6. ទោះបីអង្គជំនុំជម្រះអនុគ្រោះកង្វះនៃការយកចិត្តទុកដាក់របស់មេធាវីការពារក្តីក៏ដោយ ក៏ឯកសារនានាដែលជាកម្មវត្ថុនៃសំណើមិនស្ថិតក្នុងវិសាលភាពនៃវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុងទេ កុំថាឡើយសំណើនេះបានបំពេញតាមលក្ខខណ្ឌតម្រូវនៃ ៨៧(៤)នោះ។ ដូច្នេះ មេធាវីការពារក្តីគ្មានមូលដ្ឋានសមស្របសុំឱ្យតុលាការទទួលយកឯកសារទាំងនេះ ដោយគ្រាន់តែលើកមូលហេតុថាប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃរួមជាមួយនិងប្រភពរបស់វាឡើយ។

7. សហមេធាវីនាំមុខសូមបញ្ជាក់បន្ថែមថា ឯកសារលេខ ១ និង ៥ ដែលមានចំណងជើងថា *ក្រោមដំណក់ទឹកភ្លៀង* និងសម្រង់សង្ខេបពាក់ព័ន្ធរបស់សៀវភៅនេះ គឺមិនសមស្របសម្រាប់តុលាការយកមកពិចារណាក្នុងបរិបទនេះឡើយ។ ឯកសារលេខ ១ គឺជាសៀវភៅដែលរៀបរាប់ពីព្រឹត្តិការណ៍ទាំងឡាយក្នុងរបបខ្មែរក្រហមដោយផ្អែកតាមដំណើររឿងរបស់អ្នកដទៃ។ វាមិនមែនជាសៀវភៅដែលផ្អែកលើបទពិសោធន៍ទាំងស្រុងរបស់ដើមបណ្តឹងទេ[14]។ ឯកសារលេខ ៥ បង្ហាញ

[13] សំណើតាមវិធាន ៨៧(៤)របស់ នួន ជា ស្នើសុំឱ្យទទួលយកឯកសារទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ឯកសារ E337 ថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១៥ ត្រង់កថាខណ្ឌ ៨។

[14] សៀវភៅដែលមានចំណងជើងថា *“កាលណាយើងជួបគ្នា”* គឺជាការពិពណ៌នាចេញពីកំណត់ហេតុអ្នកស្រី អ៊ុំ សុផានី ក្នុងសម័យខ្មែរក្រហម ឯសៀវភៅដែលមានចំណងជើងថា *“ក្រោមដំណក់ទឹកភ្លៀង”* គឺមិនមែនជាការពិពណ៌នាបទពិសោធន៍ផ្ទាល់ខ្លួនទាំងស្រុងរបស់គាត់ក្នុងរបបខ្មែរក្រហមទេ។ ប្រតិចារឹក E1/251.1 ថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០១៥ ត្រង់ ERN 01059120 (“អ្នកជិតខាងខ្ញុំបាននិយាយថា “ខ្ញុំឃើញបង សុផានី ចូលចិត្តសរសេរជារៀងរាល់ថ្ងៃ។ អ៊ីចឹងបង នែឥឡូវមានគេប្រឡងប្រជែងប្រលោមលោក។ តើបងស្រី អ្នកបងចូល ចង់ប្រលងនឹងគេទេ?” ខ្ញុំក៏យកសៀវភៅ “កាលណាយើងជួបគ្នា” ហ្នឹងទៅឱ្យគេមើល។ ថានេះសៀវភៅខ្ញុំសរសេរ ដែលខ្ញុំចូលចិត្តសរសេររៀងរាល់ថ្ងៃ។ គេក៏និយាយថា “ទេ ប្រលោមលោក គេមិនៗដាក់ថ្ងៃខែអ៊ីចឹងទេ បងឯងបង្កើត តួអីបន្តិចបន្តួចទៅ ដើម្បីឱ្យទៅជាប្រលោមលោក”។ ខ្ញុំក៏ចម្លងពីសៀវភៅ “កាលណាយើងជួបគ្នា” នូវចំណុចសំខាន់ៗដូចកន្លែងបងស្រីខ្ញុំស្លាប់ កន្លែងជម្លៀសចេញទៅ ខ្ញុំដើររសាត់អណ្តែតតែលតោលក្នុងព្រៃហ្នឹង ខ្ញុំយកកន្លែងហ្នឹងខ្លះ ហើយខ្ញុំបង្កើតតួ។ ប៉ុន្តែសៀវភៅនោះ មិនមែនថាមិនមែនជាសាច់រឿងខ្ញុំបន្តិចមែន បង្កើតបន្តិចមែន ប៉ុន្តែក៏ខ្ញុំពេលខ្ញុំចុះមូលដ្ឋានឆ្នាំ១៩៨៤ គឺថារាជរដ្ឋាភិបាលឱ្យខ្ញុំចុះទៅមូលដ្ឋាន។ ខ្ញុំស្រមៃទៅសម័យកាល ប៉ុល ពត ដូច្នេះ ខ្ញុំបញ្ចូលរឿងរ៉ាវរបស់ខ្ញុំ ជាមួយព័ត៌មានផ្សេងទៀត។” ប្រតិចារឹក E1/251.1 ថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០១៥ ត្រង់ ERN 01059119 ពេលយោងទៅរក សៀវភៅដែលមានចំណងជើងថា *កាលណាយើងជួបគ្នា* អ្នកស្រីបានបញ្ជាក់ថា (“ខ្ញុំសរសេរនេះ គឺខ្ញុំយោងទៅលើកំណត់ហេតុរបស់ខ្ញុំ។ ខ្ញុំពុំដឹងថា សរសេរ លោកអានទៅរបៀបម៉េចទេ ប៉ុន្តែខ្ញុំយោងតាមកំណត់ហេតុរបស់ខ្ញុំ។ ខ្ញុំ

ពីសេចក្តីអធិប្បាយរបស់អ្នកអានអនាមិកក្នុងប្រព័ន្ធអ៊ីនធឺណិត។ គ្មានឯកសារណាមួយមានការចង្អុលបង្ហាញគ្រប់គ្រាន់ពីភាពអាចជឿជាក់បាន ដែលតុលាការត្រូវទទួលយកតាមវិធាន ៨៧(៣) ឡើយ។ តាមមូលហេតុដូចខាងលើដែរ គ្មានឯកសារណាមួយសមស្របសម្រាប់ឲ្យតុលាការទទួលយកតាមវិធាន ៨៧(៤) បានទេ ដោយសារឯការទាំងនេះមិនអាចជួយដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិតឡើយ។

8. នៅទីបញ្ចប់នេះ សហមេធាវីនាំមុខសូមបញ្ជាក់ថាអ្នកស្រី អ៊ុំ សុផានី មិនត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីដោយផ្អែកលើមូលដ្ឋាននៃអាពាហ៍ពិពាហ៍ដោយបង្ខំទេ ហើយអង្គជំនុំជម្រះមិនបានកោះអញ្ជើញឲ្យគាត់មកផ្តល់សក្ខីកម្មអំពីការរៀបការដោយបង្ខំរបស់គាត់ឡើយ[15]។ ការអះអាងរបស់មេធាវីការពារក្តីថាអ្នកស្រី អ៊ុំ សុផានី បានរងគ្រោះពីបទឧក្រិដ្ឋធ្ងន់ធ្ងរជាងអ្វីដែលគាត់បានបញ្ជាក់ក្នុងសក្ខីកម្ម គឺមិនប៉ះពាល់ដល់ភាពអាចជឿជាក់បានរបស់គាត់ឡើយ[16]។ ដូច្នេះឯកសារដែលមេធាវីការពារក្តីអះអាងថាពិភាក្សាពីអ្នកស្រី អ៊ុំ សុផានី និងការរៀបការដោយបង្ខំមិនអាចជួយដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិតអំពីហេតុការណ៍ ដែលតុលាការកោះឲ្យគាត់ផ្តល់សក្ខីកម្មបានទេ។ ផ្អែកតាមមូលដ្ឋាននេះ ឯកសារទាំង ៥ ដែលមេធាវីការពារក្តីបានស្នើ គឺគ្មានភាពពាក់ព័ន្ធតាមវិធានផ្ទៃក្នុង ៨៧(៣) ហើយមិនបានបំពេញតាមលក្ខខណ្ឌតម្រូវចាំបាច់នៃវិធាន ៨៧(៤) ឡើយ។

---

សរសេរអំពីរឿងពិតរបស់ខ្ញុំ ដែលខ្ញុំនៅសម័យ ប៉ុល ពត ហើយខ្ញុំមានការចងចាំ ដែលខ្ញុំសរសេរទុកហ្នឹង ព្រោះអីខ្ញុំសរសេរនៅឆ្នាំ១៩៨០។")

[15] ចូរអានដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅរាជធានីភ្នំពេញ ឯកសារ D406 ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០១០ ដែលប្រកាសទទួលស្គាល់ថាដើមបណ្តឹងរដ្ឋប្បវេណីគឺជាជនរងគ្រោះផ្ទាល់ពីព្យសនកម្មផ្ទាល់ខ្លួនដែលពួកគេបានទទួលរងនៅសហករណ៍ត្រាំកក់ និងជាជនរងគ្រោះដោយផ្ទាល់និងដោយប្រយោលពីព្យសនកម្មដែលពួកគេទទួលរងក្នុងអំឡុងពេលនៃការបម្លាស់ទីដោយបង្ខំចេញពីភ្នំពេញ៖ ការជម្លៀសដំណាក់កាលទី ១។

[16] គួរកត់សំគាល់ផងដែរថា ដើមបណ្តឹងរដ្ឋប្បវេណីចំនួនដ៏ច្រើនបានទទួលរងព្យសនកម្មពីបទឧក្រិដ្ឋលើសពីមួយក្នុងរបបបីឆ្នាំប្រាំបីខែ និង ១៥ថ្ងៃ(sic) ដែលស្ថិតក្នុងយុត្តាធិការពេលវេលានៃតុលាការនេះ។ ភាពអាចជឿជាក់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវរងផលប៉ះពាល់ពីការកោះហៅនិងសាកសួរដើមបណ្តឹងរដ្ឋប្បវេណីពីបទឧក្រិដ្ឋមួយ ឬមួយចំនួន និងការមិនបានសាកសួរពីបទឧក្រិដ្ឋផ្សេងទៀតឡើយ។ ជាពិសេស វាជាការពិតកាលណាបទឧក្រិដ្ឋមួយពាក់ព័ន្ធទៅនឹងអំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាយេនឌ័រ។

9. សហមេធាវីនាំមុខបានកត់សំគាល់ដោយមានការព្រួយបារម្ភ ទៅលើការមិនគោរពតាមនីតិវិធីដែលចែងយ៉ាងច្បាស់ក្នុងវិធាននៃផ្ទៃក្នុង និងការអនុវត្តន៍របស់អង្គជំនុំជម្រះ ហើយសូមស្នើឲ្យអង្គជំនុំជម្រះមេត្តាបដិសេធចោលសំណើរបស់មេធាវីការពារក្តី។

## IV. សំណើ

**អាស្រ័យដោយមូលហេតុដូចបានពោលខាងលើ** សហមេធាវីនាំមុខ សូមគោរពស្នើឲ្យអង្គចំនុំជម្រះ៖

១. បដិសេធចោលសំណើរបស់មេធាវីការពារក្តី។

សូមលោក/លោកស្រីចៅក្រម ទទួលនូវសេចក្តីគោរពអំពីយើងខ្ញុំ។

| កាលបរិច្ឆេទ | នាមនិងគោត្តនាម | ធ្វើនៅ | ហត្ថលេខា |
|---|---|---|---|
| ៤ ខែកុម្ភៈ ឆ្នាំ ២០១៥ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខ | ភ្នំពេញ | |